[SCHOOL NAME AND DATE]

ជូនដល់សិស្សានុសិស្ស និងមាតាបិតា/អាណាព្យាបាល៖

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វៀ បានផ្តល់នូវវិធីដ៏គួរឲ្យរំជួលចិត្តថ្មីពីរគឺ StudentNet (បណ្តាញសិស្ស) និង គម្រោងសិក្សាសម្រាប់សិស្សម្នាក់ៗ(ILP) ដើម្បីជួយសិស្សដើម្បីតាមដាននូវការរីកចម្រើននៃការសិក្សារបស់ពួកគេ និងរៀបគម្រោង នៃគោលបំណងសិក្សា និងអាជីព។ ឆ្នាំសិក្សានេះ ក្រសួងអប់រំតម្រូវឲ្យសាលាធ្វើការជាមួយសិស្ស ពីថ្នាក់ទី៤ ដល់ទី១២ ទាំងអស់ ឲ្យប្រើ StudentNet (បណ្តាញសិស្ស) និង គ្រោងនូវគម្រោងសិក្សាសម្រាប់សិស្សម្នាក់ៗ។ បុគ្គលិកនៅសាលា [INSERT SCHOOL NAME] នឹងធ្វើការជាមួយកូនលោកអ្នកពីដើមឆ្នាំដល់ចុងឆ្នាំ ដើម្បីប្រើវិធីទាំងនេះ ហើយយើងខ្ញុំសង្ឃឹមថាលោកអ្នកនឹងគាំទ្រដល់ការខំប្រឹងខ្នះខ្នែងនេះ។

នេះគឺជាអ្វីៗដែលលោកអ្នកអាចធ្វើ ដើម្បីចូលរួម និងគាំទ្រយើងខ្ញុំចំពោះកិច្ចការនេះ៖

- ឲ្យកូនបើកកុំព្យូទ័រចូលទៅ StudentNet ជាមួយលោកអ្នក ដើម្បីឲ្យលោកអ្នកអាចរកមើលអ្វីៗជាមួយគ្នា
- ពិនិត្យមើលរបាយការណ៍សិក្សារបស់កូននៅក្នុង StudentNet ហើយពិភាក្សាគ្នាជាមួយកូន
- ទាក់ទងទៅអ្នកផ្តល់ឱវាទនៅសាលារបស់កូនដើម្បី សួរសំណួរ រកជំនួយ និង/ឬ ផ្តល់គម្រោងសិក្សាសម្រាប់សិស្សម្នាក់ៗ ថ្មីៗ ដែលលោកអ្នក បានរៀបចំឡើងជាមួយនិងកូន
- [**សម្រាប់ថ្នាក់មត្តេយ្យ-ទី៨**] ប្រសិនបើកូនលោកអ្នកភ្លេចពាក្យសម្ងាត់របស់ពួកគេ សូមទាក់ទងទៅអ្នកផ្តល់ឱវាទនៅសាលា
- [**សម្រាប់ថ្នាក់ទី៩-ទី១២**] ប្រសិនបើកូនលោកអ្នកភ្លេចពាក្យសម្ងាត់បណ្ណោះអាសន្នរបស់ពួកគេ សូមទាក់ទងទៅអ្នកផ្តល់ឱវាទនៅសាលា។ ប្រសិនបើកូនលោកអ្នកភ្លេចពាក្យសម្ងាត់ដែលបានជ្រើសម្តងរួចហើយ សូមចូលទៅគេហទំព័រ www.philasd.org/login ហើយចុចត្រង់ពាក្យ "Forgot Your Password?" នៅក្នុងប្រអប់ "Student" ពណ៌ខៀវ ។ ហើយប្រសិនបើកូនលោកអ្នកភ្លេចចម្លើយទៅនឹងសំណួរការពារសន្តិសុខ សូមប្រាប់ទៅអ្នកផ្តល់ឱវាទនៅសាលា ឲ្យទាក់ទងទៅអ្នកផ្តល់ជំនួយខាង កុំព្យូទ័រនៅឯក្រសួងអប់រំ លេខ (២១៥) ៤០០-៥៥៥៥។
- ជំរុញកូនឲ្យប្រើ StudentNet ឲ្យបានញឹកញាប់ ដើម្បីរកមើលរបាយការណ៍សិក្សា ប្រើសៀវភៅអានដែលមាននៅក្នុងកុំព្យូទ័រ និងរកមើលអ្វីៗជាច្រើនទៀតដែលមាននៅក្នុងនោះ
- មើលតាម www.philasd.org/offices/studentnet ហើយចុចលើទំព័រ *Resource Materials* ដើម្បីយកឯកសារទាំងនោះ (ដូចជាការណែនាំសម្រាប់ គម្រោងសិក្សាសម្រាប់សិស្សម្នាក់ៗ និងគោលបំណងរបស់ SMART) ដែលអាចជួយលោកអ្នកធ្វើអ្វីៗជាមួយកូន
- ចុះឈ្មោះសម្រាប់ប្រើ FamilyNet ដោយផ្ទាល់ ដើម្បីមើលរបាយការណ៍សិក្សារបស់កូន និងពិនិត្យមើល គម្រោងសិក្សាសម្រាប់សិស្សម្នាក់ៗ របស់ពួកគេ។ លោកអ្នកត្រូវការ ថ្ងៃកំណើតកូន និង អត្តលេខ របស់សិស្ស ទើបអាចចុះឈ្មោះបាន។ ដើម្បីជ្រាបពីវិធីចុះឈ្មោះ សូមចូលទៅ https://phila.schoolnet.com/outreach/philadelphia/parents/

ព័ត៌មានពិតៗអំពី StudentNet និង ILP ដែលនៅក្នុងនេះ ផ្តល់ព័ត៌មានក្បោះក្បាយថែមទៀត។ ប្រសិនបើលោកអ្នកមានសំណួរអ្វី សូមទាក់ទងមកយើងខ្ញុំ លេខ [PHONE/EMAIL ADDRESS]។

ដោយសេចក្តីស្មោះស្ម័គ្រ

[NAME] [NAME]
អ្នកផ្តល់ឱវាទរបស់សាលា នាយកសាលា